ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិដឹកនាំការងារ
កំណែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការ

លេខ ០១២.៩៩.៨..../គ.ជ.ក.វ

រាជធានីភ្នំពេញ ថ្ងៃទី..២៣..ខែ....ធ្នូ.......ឆ្នាំ២០០៨

# សេចក្តីសម្រេច
# ស្តីពី
# ការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមការងារគណនេយ្យភាពជាតិ

## គណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលបានប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម ០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលបានប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលបានប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៥៥ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៦ ស្តីពីការបង្កើតគណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
- បានឃើញអនុក្រឹត្យលេខ ៩៤ អនក្រ.បក ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០០៦ ស្តីពីការបង្កើតក្រុមការងាររបស់គណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០២ ស្តីពីមូលនិធិឃុំ សង្កាត់
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០០២ ស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់
- យោងតាមសំណើរបស់លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ។

# សម្រេច

**ប្រការ ១.-**

បង្កើតក្រុមការងារគណនេយ្យភាពជាតិ( ហៅកាត់ថា " គ.គ.ជ " ) នៃគណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ( គ.ជ.វ.វ ) ដើម្បីធានានូវគណនេយ្យភាព តម្លាភាព និងប្រសិទ្ធភាពក្នុងការប្រើប្រាស់ថវិកាគ្រប់ប្រភពទាំងអស់ ដែលអនុវត្តដោយរដ្ឋបាលថ្នាក់ក្រោមជាតិ និងស្ថិតនៅក្រោមផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ ដែលសម្របសម្រួល និងប្រើប្រាស់រចនាសម្ព័ន្ធរបស់ គ.ជ.វ.វ និងមូលនិធិឃុំ សង្កាត់ ព្រមទាំងរួមចំណែកក្នុងការពង្រឹងការអនុវត្តការងាររបស់ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ស្របតាមគោលការណ៍ច្បាប់។

**ប្រការ ២.-**

គ.គ.ជ មានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១-ឯកឧត្តម **សក់ សេដ្ឋា** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ជាប្រធាន |
| ២-ឯកឧត្តម **លេខ ទី** | អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ | ជាអនុប្រធាន |
| ៣-ឯកឧត្តម **ចាន់ ដារ៉ុង** | អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេស ក្រសួងអភិវឌ្ឍន៍ជនបទ | ជាសមាជិក |
| ៤-អគ្គនាយករង ឬប្រធាននាយកដ្ឋានពន្ធដារ ចំនួន ០១ រូប | នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ជាសមាជិក |
| ៥-ឯកឧត្តម **ង៉ូ គីមឡេង** | អគ្គលេខាធិការរងនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ជាសមាជិក |
| ៦-ឯកឧត្តម **ឈឹម សារ៉េត** | ប្រធាននាយកដ្ឋានលទ្ធកម្មសាធារណៈ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ជាសមាជិក |
| ៧-លោក **យិន ម៉ាលីណា** | ប្រធាននាយកដ្ឋានរដ្ឋបាលមូលដ្ឋាន នៃក្រសួងមហាផ្ទៃ | ជាសមាជិកអចិន្ត្រៃយ៍ |
| ៨-លោក **លីម ម៉ិនហៃ** | ប្រធាននាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ជាសមាជិក |
| ៩-លោក **ឈាន ហៀង** | ប្រធាននាយកដ្ឋានគណនេយ្យ នៃអគ្គនាយកដ្ឋានរតនាគារជាតិ | ជាសមាជិក |
| ១០-លោក **សែត សាម៉ន** | អនុប្រធាននាយកដ្ឋានសេដ្ឋកិច្ចជនបទ នៃក្រសួងអភិវឌ្ឍន៍ជនបទ | ជាសមាជិក |
| ១១-លោក **ប្រាក់ សំអឿន** | អនុប្រធាននាយកដ្ឋានរដ្ឋបាលមូលដ្ឋាន នៃក្រសួងមហាផ្ទៃ | ជាសមាជិក |
| ១២-លោក **សី ថរិន** | ប្រធានការិយាល័យហិរញ្ញវត្ថុ នៃនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ | ជាសមាជិក |
| ១៣-លោក **សយ កុសល** | ប្រធានសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាឃុំ សង្កាត់ | ជាសមាជិក |
| ១៤-តំណាងអង្គការសង្គមស៊ីវិលចំនួន ០២ រូប | | ជាសមាជិក |

ការជ្រើសរើសតំណាងសង្គមស៊ីវិល ត្រូវកំណត់ដោយគោលការណ៍ណែនាំមួយដោយឡែករបស់ គ.ជ.វ.វ។

ក្នុងករណីសមាជិក ក.គ.ជ ណាមួយត្រូវបានផ្លាស់ប្តូរ ប្រធានក្រុម ក.គ.ជ ត្រូវរៀបចំសំណើកែសម្រួលសមាសភាពក្រុមការងារនេះឡើងវិញ និងដាក់ជូន គ.ជ.វ.វ ពិនិត្យ និងសម្រេច ដើម្បីបន្តនិរន្តរភាពដំណើរការការងាររបស់ ក.គ.ជ។

**ប្រការ ៣.-**

ក.គ.ជ មានតួនាទីជួយដល់ គ.ជ.វ.វ ក្នុងការរៀបចំនីតិវិធី បែបបទ របៀបរបបធ្វើការងារសម្រាប់ការអនុវត្តរបស់ក្រុមការងារគណនេយ្យភាពខេត្ត ក្រុង (ហៅកាត់ថា "ក.គ.ខ") ព្រមទាំងតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តការងាររបស់ ក.គ.ខ និងរាយការណ៍ជូន គ.ជ.វ.វ ។

**ប្រការ ៤.-**

ក.គ.ជ ត្រូវទទួលខុសត្រូវក្នុងការអនុវត្តការងារដូចខាងក្រោម :

- រៀបចំសេចក្តីណែនាំស្តីពីការរៀបចំកែសម្រួល និងការបង្កើត ក.គ.ខ
- សម្របសម្រួល គាំទ្រ និងពង្រឹងសមត្ថភាពដល់ ក.គ.ខ ក្នុងការអនុវត្ត នីតិវិធី តួនាទី និងភារកិច្ចរបស់ ក.គ.ខ ដើម្បីធានានូវគណនេយ្យភាព តម្លាភាព និងប្រសិទ្ធភាពក្នុងការប្រើប្រាស់ថវិកាគ្រប់ប្រភពទាំងអស់ ដែលអនុវត្តដោយរដ្ឋបាលថ្នាក់ក្រោមជាតិ និងស្ថិតនៅក្រោមផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំដែលសម្របសម្រួល និងប្រើប្រាស់រចនាសម្ព័ន្ធរបស់ គ.ជ.វ.វ និងមូលនិធិឃុំ សង្កាត់ ព្រមទាំងរួមចំណែកក្នុងការពង្រឹងការអនុវត្តការងាររបស់ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ស្របតាមគោលការណ៍ច្បាប់
- រៀបចំលិខិតបទដ្ឋាន នីតិវិធី និងគោលការណ៍ណែនាំ ដើម្បីដោះស្រាយបញ្ហានានាដែល ក.គ.ខ ទទួលបាន និងរកឃើញ
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃចំពោះដំណើរការអនុវត្តសកម្មភាពរបស់ ក.គ.ខ ដូចជា កិច្ចប្រជុំ ការស៊ើបអង្កេត និងការដោះស្រាយពាក្យបណ្តឹងតវ៉ា ព្រមទាំងការផ្សព្វផ្សាយព័ត៌មានដល់ប្រជាពលរដ្ឋទូទៅ
- រៀបចំយុទ្ធសាស្ត្រផ្សព្វផ្សាយព័ត៌មានដល់អ្នកពាក់ព័ន្ធ និងប្រជាពលរដ្ឋតាមរយៈផ្ទាំងរូបភាព សន្លឹកប័ណ្ណព័ត៌មាន វីដេអូ ការផ្សព្វផ្សាយតាមទូរទស្សន៍ វិទ្យុ និងវេទិកាផ្សេងៗ ដើម្បីលើកកំពស់ការ យល់ដឹង ការបង្កើនភាពទុកចិត្ត និងការចូលរួមរបស់ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធឱ្យកាន់តែសកម្មក្នុងការរួមចំណែកផ្តល់ព័ត៌មាន និងរាយការណ៍លើបញ្ហាភាពមិនប្រក្រតីក្នុងការអនុវត្តតួនាទី និងភារកិច្ចរបស់ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងការអនុវត្តគម្រោងនានាក្រោមការគាំទ្រមូលនិធិដែលសម្របសម្រួល និងប្រើប្រាស់រចនាសម្ព័ន្ធរបស់ គ.ជ.វ.វ
- ត្រួតពិនិត្យជាប្រចាំលើការអនុវត្តសកម្មភាពរបស់ ក.គ.ខ និងផ្តល់ព័ត៌មានត្រឡប់ទៅ ក.គ.ខ ដើម្បីពង្រឹងការបំពេញការងាររបស់ ក.គ.ខ ឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់

- សម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានា ក្នុងការគាំទ្រ ការអន្តរាគមន៍ និងការដោះស្រាយរាល់បញ្ហាផ្សេងៗ ដែលពាក់ព័ន្ធទៅនឹងកិច្ចការរបស់ក្រុមការងារគណនេយ្យភាព
- អាចទទួលពាក្យបណ្តឹងតវ៉ាពីប្រជាពលរដ្ឋតាមមធ្យោបាយផ្សេងៗ និងបញ្ជូនពាក្យបណ្តឹងតវ៉ាទាំងនោះទៅឱ្យ ក.គ.ខ ដែលពាក់ព័ន្ធដើម្បីធ្វើការដោះស្រាយ
- រៀបចំផែនការសកម្មភាព និងថវិកា ដើម្បីអនុវត្តតួនាទី និងភារកិច្ចរបស់ ក.គ.ជ
- រៀបចំរបាយការណ៍ស្តីពីការអនុវត្តការងាររបស់ខ្លួន ដើម្បីធ្វើសេចក្តីរាយការណ៍ជូន គ.ជ.វ.វ និងផ្តល់ជូនរបាយការណ៍នេះជូនដៃគូអភិវឌ្ឍន៍
- កៀរគរថវិកា និងការចូលរួមពីដៃគូអភិវឌ្ឍន៍ និងសង្គមស៊ីវិលក្នុងការគាំទ្រការអនុវត្តការងាររបស់ ក.គ.ជ និង ក.គ.ខ
- លើកអនុសាសន៍ស្តីពីដំណោះស្រាយជូន ក.គ.ខ លើករណីទាំងឡាយណាដែល ក.គ.ខ បានស្នើឡើង និងពុំមានលទ្ធភាពដោះស្រាយ
- លើកអនុសាសន៍ស្តីពីដំណោះស្រាយជូន គ.ជ.វ.វ លើករណីទាំងឡាយណាដែល ក.គ.ខ បានស្នើឡើង ហើយដែល ក.គ.ជ ពុំមានលទ្ធភាពដោះស្រាយ
- រៀបចំវេទិកាជាមួយដៃគូអភិវឌ្ឍន៍ និងសង្គមស៊ីវិល អំពីការអនុវត្តសកម្មភាពរបស់ក្រុមការងារគណនេយ្យភាព
- រៀបចំកិច្ចប្រជុំផ្លាស់ប្តូរបទពិសោធន៍រវាង ក.គ.ជ និង ក.គ.ខ រៀងរាល់ ៦ ខែម្តង ។

**ប្រការ ៥.-**

ក.គ.ជ ត្រូវមានក្រុមគាំទ្រជាជំនួយការ ដើម្បីជួយអនុវត្តកិច្ចការប្រចាំថ្ងៃ ។ សមាសភាព តួនាទី ភារកិច្ច និងរបៀបរបបធ្វើការងាររបស់ក្រុមគាំទ្រនេះ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ គ.ជ.វ.វ ។

**ប្រការ ៦.-**

ក.គ.ជ ត្រូវធ្វើការប្រជុំជាទៀងទាត់យ៉ាងតិច ១ ដង ក្នុងរយៈពេល ២ ខែ ។ ប្រសិនបើមានករណីចាំបាច់បន្ទាន់ ក.គ.ជ អាចធ្វើការកោះប្រជុំវិសាមញ្ញបាន ។

កិច្ចប្រជុំ ក.គ.ជ នឹងយកជាការបាន លុះត្រាតែមានវត្តមានសមាជិក ក.គ.ជ លើសពីពាក់កណ្តាលនៃចំនួនសមាជិក ក.គ.ជ ទាំងអស់ចូលរួមប្រជុំ ។

សេចក្តីសម្រេចនៃកិច្ចប្រជុំរបស់ ក.គ.ជ អាចចាត់ទុកជាបានការ លុះត្រាតែសេចក្តីសម្រេចនោះត្រូវបានអនុម័តដោយសម្លេងភាគច្រើននៃចំនួនសមាជិក ក.គ.ជ ដែលបានចូលរួមប្រជុំ ។ ក្នុងពេលអនុម័ត ប្រសិនបើមានសម្លេងស្មើគ្នា សម្លេងរបស់ប្រធាននៃអង្គប្រជុំមានឧត្តមានុភាព ។

**ប្រការ ៧.-**

ក្នុងកិច្ចប្រជុំលើកទី១ របស់ខ្លួន ក.ត.ជ ត្រូវធ្វើការពិនិត្យ និងអនុម័តនូវរបៀបរបបធ្វើការងារ និងប្រតិទិននៃការប្រជុំក្នុងរយៈពេលមួយឆ្នាំ ។

**ប្រការ ៨.-**

ក.ត.ជ និងមន្ត្រីក្រុមគាំទ្រមានសិទ្ធិចូលរួមកិច្ចប្រជុំរបស់ក្រុម ក.ត.ខ ដើម្បីពិនិត្យ និងសង្កេតដំណើរការប្រជុំ ប៉ុន្តែអ្នកទាំងនេះគ្មានសិទ្ធិបញ្ចេញមតិយោបល់ឡើយ លើកលែងតែមានការស្នើសុំពីអធិបតីនៃអង្គប្រជុំ ក.ត.ខ ។

**ប្រការ ៩.-**

ក.ត.ជ អាចទទួលបានការគាំទ្រទាំងផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុដោយផ្ទាល់ពីដៃគូអភិវឌ្ឍន៍នានា ។

**ប្រការ ១០.-**

រដ្ឋមន្ត្រីក្រសួង ស្ថាប័ននៃសមាជិក គ.ជ.វ.វ និងឯកឧត្តម លោក លោកស្រី ដែលមានចែងក្នុងប្រការ ២ ត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ជ. គណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់**
**វិមជ្ឈការ និងវិសហមជ្ឈការ**
**ប្រធាន**

**ស ខេង**

<u>ចម្លងជូន</u>

- ក្រសួង ស្ថាប័នជាសមាជិក គ.ជ.វ.វ
- គណៈកម្មាធិការអភិវឌ្ឍន៍ជនបទគ្រប់ខេត្ត ក្រុង

 “ដើម្បីជូនជ្រាប”

- ដូចប្រការ ២

 “ដើម្បីអនុវត្ត”

- ឯកសារ កាលប្បវត្តិ